## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom)

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៣៦រូប និងតាមប្រព័ន្ធអនឡាយចំនួន៣៧រូប សរុបចំនួន៧៣រូប។

**៤. របៀបវារៈ៖**

**ក-** មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

**ខ-** បទបង្ហាញស្តីពី វិធានការបង្ការការចម្លងមេរោគអេដស៍ ឆ្ពោះទៅសម្រេចគោលដៅ៩៥ទីមួយ បង្ហាញដោយ **លោកស្រីវេជ្ជបណ្ឌិត ទេព សំណាង** អនុប្រធានការិយាល័យបច្ចេកទេស នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

**គ-** មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. លទ្ធផល ៖**

ជាកិច្ចចាប់ផ្ដើម **ឯកឧត្តមបណ្ឌិត ឈឹម យិនជារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**ដំណើរការនៃកិច្ចប្រជុំមាន៖**

**ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសមាជិក សមាជិកានៃអង្គប្រជុំ ព្រមទាំងបានបញ្ជាក់ថា ជំងឺអេដស៍នៅតែជាចំណុចអាទិភាព ជាទិសដៅគួរឱ្យបារម្ភគឺ ៩៥ ទី១ ដែលមិនទាន់ទទួលបានលទ្ធផលល្អនៅឡើយ។ ហេតុដូច្នេះ តើយើងគួរកវិធីសាស្ត្រ ឬមធ្យោបាយយ៉ាងណា ដើម្បីសម្រេចគោលដៅ ៩៥ទី១ នៅឆ្នាំ២០២៥។

បទអន្តរាគមន៍បង្ការដែលមានលក្ខណៈសុក្រឹតជាក់លាក់ក្នុងការយកមកប្រើប្រាស់ ដើម្បីសម្រេចបាននូវការសម្រេចចិត្តបានត្រឹមត្រូវ និងទាន់ពេលវេលាដែលផ្ដោតទៅលើគោលនយោបាយលុបបំបាត់ជំងឺអេដស៍ នៅ ២០២៥ និងចីរភាពនៃកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

តាមរយៈនៃកិច្ចប្រជុំ **លោកស្រីវេជ្ជបណ្ឌិត ទេព សំណាង** អនុប្រធានការិយាល័យបច្ចេកទេស នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានធ្វើបទបង្ហាញអំពីវិធានការបង្ការការចម្លងមេរោគអេដស៍ ឆ្ពោះទៅសម្រេចគោលដៅ៩៥ទីមួយ។

-សង្ខេបការចម្លងមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងប្រទេសកម្ពុជាឆ្នាំ២០២២ សរុបចំនួន៧៦,០០០នាក់ ទទួលជោគជ័យលើការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ហើយនៅចុងឆ្នាំ២០២២នេះ កម្ពុជាសម្រេចបាន៨៦%លើគោលដៅ៩៥ទីមួយ សម្រេចបាន៩៩%លើគោលដៅ៩៥ទីពីរ និងសម្រេចបាន៩៨%លើគោលដៅ៩៥ទីបី។

- ការឆ្លងមេរោគអេដស៍ថ្មីនៅកម្ពុជាក្នុងឆ្នាំ២០២២ មានចំនួន១,៤០០នាក់ ដើម្បីឈានទៅដល់៩៥ នៅឆ្នាំ២០២៥ លុះត្រាតែអត្រាចម្លងនៅសល់តិចជាង២៥០នាក់ក្នុងមួយឆ្នាំ។

-វិធីសាស្ត្រនៃយុទ្ធវិធីជំរុញខ្លាំងក្លាសេវាបង្កាថែទាំ និងព្យាបាលសម្រាប់ក្រុមប្រឈមខ្ពស់មាន៖

- ការអប់រំតាមការជួបផ្ទាល់។
- ការអប់រំតាមបែបនិមិត្ត។
- ការតាមរក និងធ្វើតេស្តដៃគូ(PNTT)។
- ការស្វែងរកករណីតាមមិត្តភក្តិ (PDI+) ។

- ពង្រីកការកក់សេវាតាម Online ឱ្យបានគ្រប់ខេត្ត។
- បង្កើនការផ្សព្វផ្សាយ និង របៀបកក់សេវា។
- ពង្រីកសេវា PrEP ឱ្យបានគ្រប់រាជធានី ខេត្ត។
- បង្កើនការផ្សព្វផ្សាយ និងការបញ្ជូនការលេបថ្នាំបង្ការជាមុននៅពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ (PrEP) ចំពោះអ្នកដែលធ្វើតេស្តអវិជ្ជមាន។
- កញ្ចប់សេវាអប់រំផ្ទាល់មាន៖ អប់រំបង្ការមេរោគអេដស៍ដោយប្រើ SBC ៣ខែម្តង ស្រោមអនាម័យ និងទឹករំអិល ប្រឹក្សាធ្វើតេស្តរកមេរោគអេដស៍ និងស្វាយ ៦ខែម្តង បញ្ជូនទៅពិនិត្យកាមរោគ ៦ខែម្តង វាយតម្លៃកម្រិតប្រឈម ៦ខែម្តង ផ្សព្វផ្សាយ និងបញ្ជូនទៅសេវាប្រឹត បញ្ជូនទៅសេវាដែលចាំបាច់ ប្រឹត PEP ART MMT SRH GBV NSP CBTX។
- កញ្ចប់សេវាអប់រំបែបនិម្មិតមាន៖ ធ្វើផែនទីប្រព័ន្ធអនឡាញ ផលិតមាតិកាដែលមានលក្ខណៈច្នៃប្រឌិត ជជែកលេងជាមួយមិត្តភក្តិ ការចែករំលែក និងការបង្ហោះមាតិការូបភាពសហការណ៍អ្នកមានឥទ្ធិពលលើបណ្តាញសង្គម ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ឬកម្មវិធីណាត់ជួបតាមអនឡាញ ទំនាក់ទំនងពីអនឡាញ មកជួបផ្ទាល់ជាមួយអ្នកអប់រំ ឬអ្នកផ្តល់ប្រឹក្សា ផ្តល់សេវាសុខភាព (ធ្វើតេស្តឈាម ផ្តល់ស្រោមអនាម័យផ្តល់ (PrEP)។

-តើធ្វើដូចម្តេចដើម្បីធ្វើឱ្យការប្រើប្រាស់ទិន្នន័យមានប្រសិទ្ធភាពបំផុត?

- មានប្រព័ន្ធគ្រប់គ្រងទិន្នន័យ អាចទាញរបាយការណ៍ និងធ្វើការវិភាគ ផ្សេងៗ ជាប្រចាំខែ ត្រីមាស ឆ្នាំ។
- ជាលទ្ធផលនៃការប្រើប្រាស់ទិន្នន័យក្នុងការតាមដាន និងកែលំអយុទ្ធសាស្ត្រ ទិសដៅ បទអន្តរាគមន៍ដើម្បីឱ្យសម្រេចបានគោលដៅ ៩៥ ទី១។
- ប្រើប្រាស់ទីន្នន័យដើម្បីកំណត់ការផ្លាស់ប្តូរ និងការកែលម្អកម្មវិធីទៅតាមអ្វីដែលទិន្នន័យប្រាប់។
- មានប្រព័ន្ធគ្រប់គ្រងទិន្នន័យ អាចទាញរបាយការណ៍ និងធ្វើការវិភាគ ផ្សេងៗ ជាប្រចាំខែ ត្រីមាសឆ្នាំ។

កន្លងមកសង្កេតឃើញថា ខេត្តតាកែវ ខេត្តព្រះសីហនុ ដែលត្រូវយកចិត្តទុកដាក់នូវបទអន្តរាគមន៍ទប់ស្កាត់ការឆ្លងថ្មី ក្នុងចំណោមយុវជនវ័យក្មេងៗ អាយុចន្លោះពី១៥ទៅ២៤ឆ្នាំ ជាពិសេសបុរសរួមភេទជាមួយបុរសមានការកើនឡើង។

**ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** បានធ្វើការបញ្ជាក់ថា ការឆ្លងថ្មីមិនទាន់មានការថយចុះនៅឡើយ ជាការព្រួយបារម្ភ ពិសេសក្រុមប្រជាជនប្រឈម និងក្រុមយុវវ័យ ព្រមទាំងសន្យាថានឹងស្នើសុំធ្វើអន្តរាគមន៍នៅខេត្តដែលក្រុមការងារមិនបានចុះអប់រំ ឬទទួលព័ត៌មានបាន នឹងទទួលយកសំណើនៅក្នុងកិច្ចប្រជុំដែលបានលើកឡើង និងពិភាក្សាជាមួយក្រុមការងារ ដោយយើងមិនអាចធ្វើបានគ្រប់គ្នាទេ យើងត្រូវជ្រើសរើសថា តើគួរធ្វើទៅលើក្រុមណាដែលងាយប្រឈម។ ឯកឧត្តម ក៏បានបន្តទៀតថា ជាក់ស្តែងប្រទេសកម្ពុជាយើង នៅមានឧបសគ្គក្នុងការ

សម្រេចឱ្យបាននូវគោលដៅ៩៥ ទី១ ដែលនៅឆ្ងាយពីគោលដៅកំណត់ និងដែលទាមទារឱ្យយើងទាំងអស់គ្នាត្រូវបន្តរួមគ្នា រកវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពផ្សេងៗទៀត ដើម្បីសម្រេចគោលដៅនេះ។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ និងជាប្រធានអង្គប្រជុំក៏បានបន្ថែមទៀតថា ការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នារវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិដែលរួមមាន គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបនឹង មេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំទិសដៅការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ និងជាបណ្តើរៗជានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

សម្រាប់កិច្ចប្រជុំបន្ទាប់ នឹងកំណត់យកនៅថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤៕

ថ្ងៃចន្ទ ៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ត្រូវថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤

| បានឃើញ និងឯកភាព | បានពិនិត្យត្រឹមត្រូវ | អ្នកធ្វើរបាយការណ៍ |
|---|---|---|
| ប្រធានអង្គប្រជុំ | ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន | |
| បណ្ឌិត ឈឹម ឃិនដារ៉េ | | ស៊ុំ ផល្លា |